ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សីល សមាធិ បញ្ញា

# ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

## Preah Sihanouk Raja Buddhist University

## មហាវិទ្យាល័យអក្សរសាស្ត្រ

**ឯកទេស៖ វិទ្យាសាស្ត្របរិស្ថាន**

**មុខវិជ្ជា៖ ពុទ្ធសាសនា សិល្បៈ និងសោភ័ណ**

***កិច្ចការស្រាវជ្រាវ***

***ប្រធានបទ៖ ផលសិប្បៈ សិល្បៈកើតអំពីផល***



**បង្រៀនដោយលោកគ្រូសាស្ត្រាចារ្យ ព្រឿន សឿន**


**ស្រាវជ្រាវដោយក្រុមទី ១**

១. សមណនិស្សិត ម៉ៅ ទ្រា

២. សមណនិស្សិត គុន ធារិទ្ធ

៣. និស្សិត ឈួក ប៊ុនធឿន


ព.ស ២៥៦១ [ឆ្នាំទី២ ជំនាន់ទី៥] គ.ស ២០១៨

# មាតិកា

I. សេចក្តីផ្តើម ......................................................................................1

១.ផលសិប្បៈ សិល្បៈកើតអំពីផល ............................................................2

២. សិល្បៈខាងរចនាព្រះពុទ្ធរូប ..............................................................2

២.១ ប្រទេសកម្ពុជាមានព្រះពុទ្ធរូប៨បែប .................................................3

២.២ សិល្បៈខាងរចនាស្តូបចេតិយ ...........................................................5

២.២.១ ចេតិយ៤ប្រភេទ ............................................................................6

២.៣ សិល្បៈខាងរចនាប្រាង្គ-ប្រាសាទ .......................................................7

២.៤ សិល្បៈខាងរចនា វិហារ សាលា គំនូរ .................................................8

II. វិធីសាស្ត្រស្រាវជ្រាវ ............................................................................10

III. លទ្ធផល ..........................................................................................11

IV. សេចក្តីសន្និដ្ឋាន ...............................................................................12

V. ឧបសម្ព័ន្ធ ..........................................................................................13

VI. ឯកសារយោង ......................................................................................15

# អារម្ភកថា

✵✵✵✵✵✵

នៅក្នុងកិច្ចការស្រាវជ្រាវនេះក្រុម ខ្ញុំព្រះករុណាបានប្រមែប្រមូលឯកសារ និងថតរូបពីនេះផងពីនោះផងមករៀបចំចងក្រងឡើង ដើម្បីសម្រួលដល់និស្សិតជំនាន់ក្រោយដែលត្រូវសិក្សាស្រាវជ្រាវពី **មុខវិជ្ជា** “**ព្រះពុទ្ធសាសនា សិល្បៈ និងសោភ័ណ**” មួយនេះ ។

សេចក្តីទាំងអម្បាលមាន ដែលសរសេរនៅក្នុងកិច្ចការស្រាវជ្រាវនេះ គ្រាន់តែជាការសង្ខេបគោលៗតែប៉ុណ្ណោះ បើសិស្សនិស្សិតជំនាន់ក្រោយៗចង់ចេះចង់ដឹងឲ្យបានជ្រៅជ្រះជាងនេះគឺ ជៀសមិនផុតពីស្វ័យសិក្សា ស្រាវជ្រាវដោយខ្លួនឯងឡើយ ។

អាស្រ័យដូចនេះ ខ្ញុំព្រះករុណាជាក្រុមទី១ រីករាយរង់ចាំទទួលការរិះគន់ និងកែតម្រូវ ដើម្បីស្ថាបនា ពីសំណាក់មិត្តអ្នកអាន សមណនិស្សិត-និស្សិត សិក្ខាកាម សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ លោក លោកស្រីទាំងអស់ដោយមេត្រី ។

ខ្ញុំព្រះករុណាជានិស្សិត ឆ្នាំទី២ ក្រុមទី១ សូមថ្លែងអំណាអរព្រះគុណចំពោះ **លោកគ្រូសាស្ត្រាចារ្យ ច្រើន សឿន** ដែលទទួលបន្ទុកបង្ហាត់បង្រៀននូវ **មុខវិជ្ជា ព្រះពុទ្ធសាសនា សិល្បៈ និងសោភ័ណ** ដោយយកចិត្តទុកដាក់ក្នុងការបង្រៀនអស់ពីកម្លាំងកាយចិត្ត ហេតុដូចនេះហើយក្រុមខ្ញុំ ព្រះករុណាសូមប្រគេនពរលោកគ្រូអោយមានព្រះសុខភាពល្អ និងជួបនូវព្រះពុទ្ធពរទាំងឡាយបួនប្រការ គឺ **អាយុ វណ្ណៈ សុខ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

ភ្នំពេញថ្ងៃ ០២រោច ខែ មាឃ ពុទ្ធសករាជ ២៥៦១

# I. សេចក្តីផ្តើម

ពាក្យថា **សិល្បៈ** ជាពាក្យដែលយើងធ្លាប់និយាយមកដោយស៊ប់ស៊ាំដែរហើយ ប៉ុន្តែវេលា នេះ ជពេលចាំបាច់ក្នុងការសំដែងអំពីសិល្បៈដែលជាប់ទាក់ទងក្នុងផ្លូវពុទ្ធសាសនា ដូចសេច ក្តីបរិយាយតទៅនេះៈ

**សិល្បៈ** ជាភាសាសំស្រ្កឹត សិប្បៈ ជាភាសាបាលីប្រែជា ភាសាខ្មែរថា “ ការឈ្លាសវៃ ដោយដៃ ការប៉ិនប្រសប់ ជំនាញដ៏ថ្នឹក ហត្ថកម្មដ៏ស្ទាត់ជំនាញ” ។

**សិល្បៈ** ជាឈ្មោះវិជ្ជាបច្ចេកទេស ដែលប្រកបដោយហត្ថកម្មចាំដៃ ឆ្លៀវឆ្លាសដោយអំណាចនៃការហាត់រៀន ការអប់រំរឿយៗ គឺថាវិជ្ជាកម្មណាដែលគេបានព្យាយាមសិក្សាធ្វើដោយផ្ទាល់ដៃ ដរាបដល់ថ្នឹកចាំស្ទាត់ ប្រាកដបាក់ដូចជាចំលាក់ជាប់នៅក្នុងចិត្ត ឥតភាន់ច្រឡំ ឥត ភ្លេច វិជ្ជាកម្មនោះឈ្មោះថា សិល្បៈទាំងអស់។

ពាក្យថា **សិល្បៈ** បើប្រែតាមធាតុថា “ វិជ្ជាកម្មដែលគួរសិក្សា ដែលគួរសេពគប់ ដែលគួរ ចូលចិត្ត” ដូចបាលីវិគ្រោះថា “**អត្តនោ ហិតមាសីសន្តេហិ សិឝិយតេតិ សិប្បំ** វិជ្ជាកម្មណា ដែល បុគ្គលអ្នកប៉ុនប៉ងនូវប្រយោជន៍ដើម្បីខ្លួនគួរសេពគប់ វិជ្ជាកម្មនោះហៅថាសិប្បៈ(សិល្បៈ)” មួយទៀតថា **សិក្ខិតព្វន្តិ សិប្បំ** វិជ្ជាកម្មដែលគប្បីរៀន ហៅថាសិប្បៈ(សិល្បៈ)។

**សិល្បៈ** បើចែកតាមលក្ខណៈ (គ្រឿងសំគាល់) មានបីយ៉ាង ដូចសេចក្តីរៀបរាប់ព្រម ទាំងអធិប្បាយតទៅនេះៈ

លក្ខណៈនៃសិល្បៈ(ហៅតាមបាលីថាសិប្បៈ) មាន៣យ៉ាងគឺៈ

១. **អភិធេយ្យសិប្បៈ** សិល្បៈដោយឈ្មោះ

២. **ហេតុសិប្បៈ** សិល្បៈកើតពីហេតុ

៣. **ផលសិប្បៈ** សិល្បៈកើតពីផល។

តែក្នុងនេះផងដែលក្រុមខ្ញុំព្រះករុណាលើកយក **ផលសិប្បៈ** មកបកស្រាយក្នុងកិច្ចការស្រាវជ្រាវនេះដោយសង្ខេបតែប៉ុណ្ណោះ។

# ១.ផលសិប្បៈ សិល្បៈកើតអំពីផល

**សិល្បៈ** ដែលសង្គ្រោះថា កើតអំពីផលនោះ គឺ សំដៅយករូបវត្ថុផ្សេងៗមានចេតិយ ឬព្រះពុទ្ធរូបជាដើម ដែលបុព្វបុរសបានសាងទុកមកហើយ ដោយហុចអោយយើងបានឃើញដំណាងស្នាដៃស្ទាត់ជំនាញឬមិនស្ទាត់ជំនាញ ជារូបមានបែបភាពទ្រង់ទ្រាយ មានក្បាច់រចនាតាមជំនាន់ តាមសម័យជូនផលដល់យើងដើម្បីអោយយើងឃើញបែបយ៉ាងរបស់វប្បធម៌ នៃបុព្វបុរសតាមសម័យនោះៗ ។ ពាក្យថា “ផល” ប្រែថា “កំរៃ ផ្លែឈើ សេចក្ដីចំរើន សេចក្ដីរុងរឿង សេចក្ដីសំរេចដូចបំណង លាភយស រង្វាន់” ។

ត្រង់ពាក្យថា **សិល្បៈ** កើតអំពីផលនោះសំដៅយកការហាត់រៀនក្នុងផ្លូវសិល្បៈរបស់មនុស្ស ដែលសំលឹងឃើញផលដែលត្រូវបាន ការហាត់រៀននោះក៏ចេះតែខំតស៊ូមិនខ្លាចឧបសគ្គណាមួយដោយមានបំណងចំពោះផលជានិទស្សន៍ មួយទៀតសិល្បៈនេះរាប់ថាជាផ្លូវអាជីព មួយដ៏ប្រសើរដែលនាំអោយមនុស្សមានជីវភាពខ្ពង់ខ្ពស់ **ឧទាហរណ៍:** ដូចជាសិល្បៈខាងការ **រចនាព្រះពុទ្ធរូប, ស្តូប ,ចេតិយ ,ប្រាង្គប្រាសាទ, វិហារ ,សាលា, គំនូរ** ,និងការរចនាផ្សេងៗ របស់បុព្វបុរសដែលវិវត្តមកដល់យើងសព្វថ្ងៃ អោយយើងបានឃើញជាភស្តុតាងយ៉ាងជាក់ស្តែង ។ សិល្បៈរបស់យើងជាន់ក្រោយឈ្មោះថា កើតមកអំពីផលសិល្បៈនៃបុព្វបុរសដែលបានផ្តល់ ទស្សនៈអោយយើង ។ រូបភាពទាំងអស់ដែលបុព្វបុរសខ្មែរកសាងឡើងដោយថ្មក្តី ដោយតដ្ឋក្តី ឈ្មោះថាជារូបសិល្បៈ ស្ថាពរ មានមកយូរហើយ ដើម្បីជានិទស្សន៍ បង្ហាញយើងជាន់ក្រោយ។

# ២. សិល្បៈខាងរចនាព្រះពុទ្ធរូប

ព្រះពុទ្ធរូប បើតាមអ្នកប្រាជ្ញប្រវត្តិសាស្ត្រគ្រាច់រង្គាត់ស្រាវជ្រាវរកបុរាណវត្ថុក្នុងប្រទេសផ្សេងៗ មានប្រទេសឥណ្ឌាជាដើម គេឃើញព្រះពុទ្ធរូបច្រើនបែប ប៉ុន្តែបើទុកជាយ៉ាងណា ក៏ព្រះពុទ្ធរូបនោះៗ ប្លែកពីរូបមនុស្សធម្មតាដែលអាចអោយអ្នកផងឃើញហើយ គួរអោយស្គាល់ បានភ្លាមថា ជារូបព្រះពុទ្ធ។ មួយទៀត ព្រះពុទ្ធរូបដែលគេឆ្លាក់ថ្មក្តី ខ្លឹមឈើក្តី គេតែងតម្រូវចិត្ត នៃពុទ្ធសាសនិកជនផង អោយ

ត្រូវតាមមហាបុរិសលក្ខណៈនៃព្រះសម្មាសម្ពុទ្ធផង ។ ប៉ន្តែពួក អ្នកសិប្បវ័ន្ត ដែលកសាងព្រះពុទ្ធរូបនោះទោះបីអំពីថ្មក្តី ខ្លឹមឈើក្តី ឬគំនូរក្តី ច្រើនតែធ្វើទៅ តាមបែបភាពទ្រង់ទ្រាយមុខមាត់របស់ជាតិខ្លួនឯងជាដរាប មិនសូវខុសអំពីមុខមាត់របស់ជាតិ ខ្លួនបានឡើយ ដែលនាំអោយយើងស្គាល់បានថា ជាការរចនារបស់ជាតិនេះ ជាតិនោះជា ប្រាកដ។

បើតាមសេចក្តីរាយការរបស់អ្នកប្រាជ្ញ ដែលស្វែងរកបុរាណវត្ថុឃើញថា ព្រះពុទ្ធទើបតែ នឹងកើតមានឡើង ក្នុងកាលខាងក្រោយដែលពុទ្ធសករាជកន្លងទៅបានជាង៤០០ឆ្នាំ ហើយពុំមែនកើតឡើងក្នុងកាលព្រះអង្គគង់ព្រះជន្មនៅឡើយនោះទេ ។ ព្រះពុទ្ធរូបដែលកើតមុនដំបូង បង្អស់ នៅក្នុងប្រទេសគន្ធារៈ ដោយព្រះបាទកនិស្កៈ ជាក្សត្រមួយអង្គ ជាជាតិក្រិកជាប់រាជវង្សតមកអំពីព្រះបាទអាឡេកសង់ដ្រ៍ ដែលមានឥទ្ធិពលពង្រីកអាណាចក្រចូលមកក្នុងប្រទេ សឥណ្ឌាក្នុងកាលពុទ្ធសតវត្សរ៍ទី៤។ បន្ទាប់មកពួកសិប្បវ័ន្តជាតិក្រិកខ្លះ ជាតិឥណ្ឌាខ្លះចេះតែ កសាងព្រះពុទ្ធរូប ដោយការឆ្លាក់ថ្មក៏មាន ខ្លឹមឈើក៏មានតៗគ្នាតាំងពីពេលនោះមក ។

# ២.១ ប្រទេសកម្ពុជាមានព្រះពុទ្ធរូប៨បែប

១. **ព្រះពុទ្ធរូបសមាធិ** គង់ពត់ព្រះភ្នែនមានព្រះហស្ថស្តាំផ្ងារលើព្រះហស្ថឆ្វេង តម្រួត លើព្រះភ្នែន ហៅថា **វិតក្កមុទ្រា** ។

២. **ព្រះពុទ្ធរូបមារវិជ័យ** (កាលផ្ចាញមារ) គង់ពត់ព្រះភ្នែនដូចព្រះពុទ្ធរូបសមាធិដែរ ប៉ុន្តែព្រះ ហស្តស្តាំផ្កាប់លើព្រះឧរុ (ភ្លៅ) ចង្អុលចុះទៅផែនដី ព្រះហស្តឆ្វេងផ្ងារដាក់លើព្រះឧរុ ហៅថា **ភូមិស្បស៌មុទ្រា** ។ ព្រះពុទ្ធបែបនេះ កាលបើគេគូរនៅជញ្ជាំងវិហារ ឬលើផ្ទាំងសំពត់ ឃើញ សុទ្ធតែមានរូបពួកពលមារាធិរាជ កាន់អាវុធរាល់ដៃ ។

៣.**ព្រះពុទ្ធសំដែងធម្មចក្រ** គង់ពត់ព្រះភ្នែនមានព្រះហស្តស្តាំក្តោបម្រាមធ្វើជាវង់មូល ដូចជាកង់រទេះ ព្រះហស្តឆ្វេងធ្វើអាការៈដូចព្រះហស្តស្តាំក៏មាន ដាក់លើព្រះឧរុក៏មានហៅថា **ធម្មចក្រ មុទ្រា**។

ព្រះពុទ្ធរូបបែបនេះ កាលបើគេគួរ តែងតែមានបញ្ចវគ្គិយភិក្ខុ កំពុងអង្គុយគោរព ស្តាប់ធម្មចក្ក ប្បវត្តនសូត្រ ដែលជាបឋមទេសនា ។

**៤.ព្រះពុទ្ធរូបប្រទានអភ័យ** ជាតំណាងកាលដែលព្រះអង្គសំដែងធម៌ប្រោសសត្វក្នុងទីណា មួយ មានព្រះកាយឈរក៏មាន គង់ពត់ព្រះភ្នែនក៏មាន ព្រះហស្តស្តាំវាចេញទៅមុខ ព្រះហស្ត ឆ្វេងសំយុងចុះ ហៅថា **អភយមុទ្រា** ។

**៥.ព្រះពុទ្ធរូបប្រទានពរ** មានព្រះហស្តទាំងពីរសំយុងចុះបែរបាតព្រះហស្តទៅខាងមុខ ទ្រង់គង់ពត់ព្រះភ្នែនក៏មាន ទ្រង់ឈរក៏មានជាតំណាងកាលបរិស័ទណាមួយចូលមកថ្វាយបង្គំ ដោយត្រូវការចង់ជួបចង់ឃើញក្តី ក្រាបទូលសួរធម៌អាថ៌ចំពោះព្រះអង្គក្តី ហៅថា **វរមុទ្រា** ។

**៦. ព្រះពុទ្ធរូបទ្រង់ឈរឱបបាត្រ** ជាតំណាងកាលដែលព្រះអង្គទ្រង់និមន្តបិណ្ឌបាត្រ ហៅ **ថា បាត្រាទានមុទ្រា** ។

**៧.ព្រះពុទ្ធរូបទ្រង់ផ្ទំ** ជាតំណាងកាលដែលព្រះអង្គផ្ទំផ្អៀងព្រះកាយទៅខាងស្តាំព្រះបាទ ឆ្វេងតម្រួតលើព្រះបាទស្តាំ ដោយទ្រង់ផ្ទំធម្មតាក្តី ផ្ទំលើមញ្ចាសនៈជាអនុដ្ឋានសញ្ញា ទ្រង់ បរិនិព្វានក្តី ហៅថា **សយនមុទ្រា** ។

**៨.ព្រះពុទ្ធរូបនាគប្រក់ៈ** ជាតំណាងកាលព្រះអង្គគង់នៅក្លឹស្រះមុចលិន្ទ ដែលោក្នុងពេល នោះមានភ្លៀងបង្អុរខ្លាំង មាននាគរាជមកពេនព័ទ្ធព្រះអង្គបើកពពារគ្របបាំងលើព្រះអង្គ ដើម្បី ការពារភ្លៀង ។

ពាក្យថា **"មុទ្រា"**នេះជាពាក្យសំស្រ្កឹត បាលីថា **"មុទ្ទា"** ប្រែជាខ្មែរថា " គ្រឿងសំគាល់, បែបយ៉ាង, បែបយ៉ាង, អាការ, កាយវិការ, ត្រា, សញ្ញា" ។

ព្រះពុទ្ធរូបទាំង៨បែបនេះ ជារូបដែលគេយកថ្មមកឆ្លាក់ក៏មានយក ចម្លាក់ពុម្ពលាយស៊ី ម៉ងត៍នឹងខ្សាច់បោះពុម្ពក៏មាន ឥឡូវនេះគេច្រើនតែបោះពុម្ព ។ ព្រះពុទ្ធដែលមានគ្រឿងសំគាល់ផ្សេងៗគ្នានេះជាបែបសិល្បៈនៃបុព្វបុរសជាតិខ្មែរ ជាពុទ្ធសាសនិកខាងនិកាយថេរវាទ ដែលគួរគោរពគួរជឿបានដោយពិត ព្រោះជារូបដែលកសាងត្រូវតាមគោលរឿងពុទ្ធប្បវត្តិ ។ ព្រះពុទ្ធ រូបទាំង៨ បែបនេះនៅប្រទេសខ្មែរយើង គេមិនគ្រាន់តែរចនាដោយឆ្លាក់ឈើឬបោះពុម្ពដោយ ស៊ីម៉ងត៍ទេ ឃើញគេគូរនៅជញ្ជាំងវិហារក៏មាន គួរលើផ្ទាំងសំពត់ក៏មាន លើផ្ទៃកញ្ចក់ក៏មាន គឺ គូរតាមរឿង

ពុទ្ធប្រវត្តិឬទសជាតក៏ មានរូបមួយបែបទៀតដែលអ្នកស្រុកហៅថា រូបស្តេចចក្រ ឬជារូបព្រះមេត្តេយ្យពោធិសត្វ មានទ្រង់មកុដ សង្វារ ខ្សែសុរងនឹងចិញ្ចៀនដូចរូបស្តេចទ្រង់ មកុដ ឬរូបស្រីល្ហៃន ។

ព្រះពុទ្ធរូបនាគប្រក់ នៅប្រទេសឥណ្ឌា មិនដែលឃើញមានទេមានតែក្នុងប្រទេសខ្មែរ ដែលកើតឡើងដោយសិល្បៈខ្មែរក្នុងសម័យខាងក្រោយដែលគេកសាងតាមរឿងពុទ្ធប្បវត្តិ ។

# ២.២ សិល្បៈខាងរចនាស្តូបចេតិយ

**ស្តូប** ជាគារវត្ថុ ជាទីបញ្ចុះសព ឬអដ្ឋិធាតុរបស់បុគ្គល មានមាតាបិតាជាដើម ដែលគេគួរ គោរព។ រូបភាពស្តូបមានរាងមូលខាងក្រោមរីកធំ ត្រអាក ខាងលើរៀវស្រួចដូចអកកំបោរក៏មានរាងទាលដូចផ្តិលផ្កាប់ក៏មាន ដែលគេកសាង ដោយពូនដីជាពំនូកក៏មានកសាងដោយឥដ្ឋដោយថ្មក៏មាន ស្តូបគ្រប់បែប ច្រើនតែមិនសូវមានក្បាច់រចនាទេ ច្រើនតេលាងរលីងជុំវិញ ។ ពាក្យថា “ ស្តូប” ជាភាសាសំស្ក្រឹត បាលីថា “ ថូប” គឺគោលជាគ្រឿងចំណាំទីកន្លែងអដ្ឋិ ធាតុសម្រាប់គោរពបូជា ។

**ចេតិយ** ជាឈ្មោះគារវវត្ថុដូចស្តូបដែរ។ពាក្យថា “ ចេតិយ” ប្រែថា ទីដែលគួរគោរព គួរបូជា។ ចេតិយមានទំហំកំពស់ធំខ្ពស់ជាងស្តូប ទាំងតួរាងរៅច្រើនតែប្រកបក្បាច់រចនាផ្សេងៗគ្នាគេកសាងដោយឥដ្ឋ ថ្មក៏មានដោយស៊ីម៉ងត៍ក៏មាន ។ ចេតិយប្រដាប់ដោយកំពូលរៀវស្រួចក៏មានដាក់ឆត្ររួតធ្វើដោយស្ពាន់ត្រង់កំពូលក៏មាន កំពូលមានមុខ៤ដូចជាមនុស្សដែលគេច្រើន ហៅថា “ មុខព្រហ្ម” ក៏មាន ។ ចេតិយដែលធ្វើជាកំពូលមុខព្រហ្មនេះ ដោយធ្លាប់ជាប់ទាក់ទង នឹងសាសនាព្រាហ្មណ៍ ដោយហេតុសាសនាព្រាហ្មណ៍ តែងគោរពនមស្ការចំពោះព្រះព្រហ្មដែលបិននៅឋានព្រហ្ម ដោយហេតុថា ព្រះព្រហ្មមានធម៌ ៤ ប្រការគឺ **មេត្តា ករុណា មុទិតា ឧបេក្ខា** ។ មួយទៀតខាងអ្នកកាន់ពុទ្ធសាសនាមហាយានថារូបដែលមានមុខ៤នេះជារូបព្រះពោធិសត្វអវលោកិតេស្វរៈដែលគេកសាងទុកគោរពនមស្ការ

នោះសុទ្ធតែមានមុខ៤សម្លឹងចុះ ក្រោមដើម្បីសំគាល់ថា លោកតែងប្រមើលសុខទុក្ខមនុស្សលោកទាំងនាមរបស់ **អវលោកិតេស្វរៈ** គេតែងហៅថា **សាមន្តមុខ** ប្រែថា “ មានមុខជុំវិញ” ។

នៅប្រទេសកម្ពុជាយើង រូបភាពចេតិយមានច្រើនបែបណាស់ ឥតដូចគ្នាទេ ប្លែកទៅតាម ស្នាដៃរបស់ពួកសិល្បករដែលអាចធ្វើបាន ដើម្បីបញ្ចុះអដ្ឋិធាតុរបស់អ្នកមានគុណ អោយសមគួរដល់កិត្តិយសរបស់គេអ្នកមានភោគសម្បត្តិ ឬអោយសមរម្យដល់តម្លៃគុណនៃលោកអ្នកមានគុណមានមាតាបិតាជាដើម ។ រូបរាងទ្រង់ទ្រាយទំហំកំពស់ចេតិយទាំងអស់ បើទុកជាច្រើនបែប ដោយជំនាញសិល្បករយ៉ាងណាក៏ដោយ គង់រួមចូលក្នុងប្រទេសចេតិយ៤យ៉ាងប៉ុណ្ណោះ។

# ២.២.១ ចេតិយ៤ប្រភេទ

**១.ធាតុចេតិយៈ** ចេតិយសម្រាប់បញ្ចុះព្រះបរមសារីរិកធាតុនៃព្រះពុទ្ធ ឬសារីរិកធា តុនៃព្រះបច្ចេកពុទ្ធ ព្រះអរហន្តនឹងស្តេចចក្រពត្រ ប៉ុន្តែបើពោលតាមសម័យនិយម សូម្បីចេតិ យដែលបញ្ចុះអដ្ឋិធាតុសាមញ្ញជន ក៏គេហៅថា ធាតុចេតិយបានដែរ ។

**២.ធម្មចេតិយចេតិយៈ** សម្រាប់តំកល់ព្រះធម្មក្ខន្ធ(ព្រះត្រៃបិដក)ឬហៅធម្មមន្ទីរសម្រាប់ទុកគម្ពីរដីកាក៏បាន ។

**៣.បរិភោគចេតិយៈ**ចេតិយសម្រាប់បញ្ចុះគ្រឿងបរិក្ខាររបស់ព្រះសម្មាសម្ពុទ្ធមានវត្ថ ពន្ធចង្កេះនឹងធម្មក្រកជាដើម ។

**៤.ឧទ្ទេសិកចេតិយៈ** ចេតិយដែលសាងចំពោះព្រះសម្មាសម្ពុទ្ធដើម្បីនមស្ការគោរព បូជាសូម្បីព្រះពុទ្ធរូបក៏រាប់ថាឧទេសិកចេតិយដែរ ។

បើតាមមហាបរិនិព្វានសូត្រក្នុងកាលដែល ព្រះសម្ពុទ្ធទ្រង់ព្រះអាពាធទ្រង់សំដែងចំពោះ ពួកភិក្ខុមានព្រះអានន្ទជាប្រធានថា“ **ចត្តារោ មេ ភិក្ខវេ ថូបារហាបុគ្គលា សម្មាសម្ពុទ្ធោ បច្ចេកពុទ្ធោ អរហា ចក្កវត្តី រាជា**” ប្រែថា ម្នាលភិក្ខុទាំងឡាយបុគ្គល៤ពួកនេះគឺ ព្រះសម្មាសម្ពុទ្ធ ១ព្រះបច្ចេកពុទ្ធ១ ព្រះអរហន្ត១ ស្តេចចក្កពត្រ១ គួរដល់ការបញ្ចុះក្នុងស្តូប ។

បុគ្គល ៤ ពួកខាងលើនេះជាបុគ្គលជាន់ខ្ពស់បំផុតជាទីគោរពសក្ការបូជារបស់ពុទ្ធបរិស័ទ រាជបរិស័ទដោយពិត។យើងជាពុទ្ធបរិស័ទសម័យជាន់ក្រោយមិនអាចនឹងស្វែងរកព្រះអដ្ឋិធា តុបុគ្គលជាន់ខ្ពស់នោះមកបញ្ចុះក្នុងចេតិយបានដោយងាយឡើយមានតែព្រះអដ្ឋិធាតុនៃព្រះ មហាក្សត្រិយ៍អដ្ឋិធាតុមាតាបិតាគ្រូអាចារ្យនឹងរដ្ឋបុរសប៉ុណ្ណោះទុកជាទីគោរពបូជារបស់យើងដែរហើយ។

ចេតិយ បើតាមប្រវត្តិការណ៍ក្នុងគម្ពីរព្រះពុទ្ធសាសនាថាជាវត្ថុស័ក្តិសិទ្ធិមួយដែលគេសាងទុកជាទីគោរពបូជា មានមកតាំងពីព្រេងព្រឹទ្ធមុនសម័យពុទ្ធកាលដែលមានឈ្មោះថា **បាវាឡចេតិយ សារន្ទទចេតិយ** ជាដើម ។

## ២.៣ សិល្បៈខាងរចនាប្រាង្គ-ប្រាសាទ

ពាក្យថា“ ប្រាង្គ” ជាពាក្យសំស្រ្កឹត រាប់ថាជាគារវត្ថុដែលមានទ្រង់ទ្រាយដូចប្រាសាទដែរ ប៉ុន្តែមានទំហំកំពស់តូចទាបជាងប្រាសាទហើយច្រើនតែមានរាង ៤ជ្រុងខ្ពស់ច្រឡោ មានកំពូលខ្ពស់ គេសាងលើទីលានខ្ពស់មួយថ្នាក់ ឬពីរបីថ្នាក់ ។ពាក្យថា“ ប្រាង្គ” ប្រែថាសេនាសនៈមានតួរាងប្រាកដស្មើរដោយប្រាសាទឬថាមានគម្រោងដូចប្រាសាទប្រាង្គនេះគេតែងធ្វើដោយឥដ្ឋ ឬថ្ម មានក្បាច់រចនាសម្រាប់បញ្ចុះសម្រាប់ដំកល់អដ្ឋិធាតុដូចចេតិយដែរ ។

ពាក្យ“**ប្រាសាទ**” ជាពាក្យសំស្រ្កឹតដែរបាលីថា “ បាសាទ” ប្រែថា គ្រឹះស្ថានជាទីញុំាងចិត្តអោយជ្រះថ្លា,គ្រឹះស្ថានគួរអោយសប្បាយ។ ប្រាសាទ គឺផ្ទះធំទូលាយខ្ពស់មានកំពូលក្តី ឥតកំពូលក្តីមានរចនាក្បូរក្បាច់ក្តី មិនមានក្តី ដែលល្អប្លែកអស្ចារ្យគួរអោយកោតសរសើរដូចយ៉ាងប្រាសាទអង្គរធំប្រាសាទបាយ័នប្រាសាទអង្គរតូចជាដើម។ ប្រទេសកម្ពុជាយើងមានប្រាសាទអង្គរជាគ្រឿងបង្ហាញនូវសិល្បៈរបស់វិស្វករខ្មែរសម័យបុរាណដល់ជនបរទេស។ ប្រាសាទអង្គរទុកជាគោលចារឹកនៃប្រទេសកម្ពុជាឬជា មុទ្រាមួយដ៏ធំបផុតរបស់ជាតិខ្មែររាប់ថាជាផលនៃសិល្បៈរបស់បុព្វបុរសខ្មែរ។ប្រជាជន ច្រើនប្រទេសដែលបានមកមើលប្រាសាទអង្គរច្រើនតែលាន់មាត់ស្ងើច សរសើរសិល្បៈរបស់បុព្វរសយើង។

តាមអ្នកប្រាជ្ញបរទេសខាងបុរាណវត្ថុដែលបានស្គាល់ប្រវត្តិការណ៍អង្គរឃើញថាវិស្វករអ្នកកសាងប្រាសាទអង្គរជាមនុស្សបច្ចេកទេស ដោយសិល្បៈយើងឆើត

ក្នុងលោក។ ប្រាសាទអង្គរ ទុកជានិមិត្តរូបមួយដ៏អស្ចារ្យដែលជាស្នាដៃរបស់សិល្បករនៃជនជាតិខ្មែរសម័យបុរាណពុំមែនជនបរទេស ឬទេវបុត្រណាមួយមកសាងប្រាសាទអង្គរទេ។

# ២.៤ សិល្បៈខាងរចនា វិហារ សាលា គំនូរ

**វិហារ** ប្រែថា” លំនៅ,ទីជ្រកកោន,ទីនៅអាស្រ័យ” ។ ពាក្យថា“ វិហារ” នេះបានដល់សេនាសនៈគ្រប់យ៉ាងទាំងកុដិសាលាធំតូច ឬទីវត្តទាំងមូលរបស់បព្វជិតពុទ្ធសាសនិកប៉ុន្តែខ្មែរយើង ច្រើនហៅតាមទម្លាប់ចំពោះតែឧបោសថាគារ( រោងឧបោសថ)ដែលមានព័ទ្ធសីមាជា វិហារ។ បែបភាពទ្រង់ទ្រាយនិងការរចនារបស់វិហារនៅប្រទេសយើងហាក់ដូចជាចេញមកអំពី សិល្បៈរបស់ជាងតែម្នាក់ដោយហេតុឃើញវិហារគ្រប់ស្រុកខេត្តស្រដៀងៗគ្នាគឺមានរាងមាន របៀងមាននាគមានជហ្វាដងក្តារ,មានហោជាង,មានក្បាច់រចនាប្រហែលៗគ្នា។ វិហារដែលកសាងក្នុងសម័យមុនច្រើនតែធ្វើដោយឈើឥឡូវនេះច្រើនតែកសាងដោយគ្រឿងបេតុងអាម៉េ ឬដោយឥដ្ឋ។ ព្រះពុទ្ធរូប ស្តូបចេតិយ ជាដើមនេះរាប់ថាជាគោលចារឹកនៃព្រះពុទ្ធសាសនា ជាវត្ថុស្ថាពរនៃប្រទេសកម្ពុជាតទៅ។

**សាលា** ច្រើនសំដៅយកសេនាសនៈសម្រាប់ប្រើប្រាស់តាមកាលវេលាមិនមែនជា កន្លែងសម្រាប់ដេកនៅប្រក្រតីទេដូចឧបដ្ឋានសាលាក្នុងវត្តសម្រាប់ពុទ្ធបរិស័ទប្រើប្រាស់តាមកាលម្តងៗសិក្ខាសាលាសម្រាប់តែចូលរៀនប៉ុណ្ណោះជាដើមពុំមែនសម្រាប់ដេកនៅឡើយ។ ឧដ្ឋានសាលាគ្រប់វត្តក៏មានបែបភាពប្រហែលៗគ្នាដែរ។គំនូររូបព្រះសម្មាសម្ពុទ្ធតាមរឿងបឋមសម្ពោធិឬទសជាតក៏ក្នុងប្រទេសយើងដែល ជាងគំនូរបានគូរទៅលើក្រដាសលើផ្ទាំង សំពត់ឬគូរនៅជញ្ជាំងវិហារជាសិល្បៈដែលទាក់ទងលើ ព្រះពុទ្ធសាសនាទាំងអស់ ។

**គំនូររូប** ព្រះសម្មាសម្ពុទ្ធតាមរឿងបឋមសម្ពោធិ ឬ ទសជាតក៏ក្នុងប្រទេសយើងដែលជាងគំនូរបានគូរទៅលើក្រដាស លើផ្ទាំងសំពត់ឬគូរនៅជញ្ជាំងវិហារ ជាសិល្បៈដែលទាក់ទងលើព្រះពុទ្ធសាសនាទាំងអស់។

សិល្បៈគ្រប់យ៉ាងរបស់ជនជាតិខ្មែរយើង ដែលកើតមានឡើង ច្រើនតែយកបែបគម្ពីរព្រះពុទ្ធសាសនា ដោយបានសិក្សារៀនសូត្រ បានដឹងរឿងដឹងប្រវត្តិការណ៍ក្នុងផ្លូវព្រះពុទ្ធសាសនា ហើយអាចប្រតិដ្ឋយករឿងនោះៗមកគូរជារូបភាពឲ្យឃើញប្រាកដឡើង ដោយយកព្រះពុទ្ធសាសនាជាទ្រឹស្តី សូម្បីព្រះឥន្ទ, ព្រះព្រហ្ម, ទេវតា, នរក, ប្រេត, យក្ស, ដែលមិនធ្លាប់បានឃើញសោះ ក៏អាចគូរកើតទោះបីគំនូររូបនោះៗ ដូចមែនក្តី មិនដូចក្តី ឲ្យគួរសន្និដ្ឋានយកបានក៏ចេះតែគូរតៗតាមគ្នាមកទុកជាអ្នកសិល្បៈណាមួយ ក៏មិនអាចចាប់កំហុសគំនូរទាំងនោះបានដោយហេតុគ្មានរូបព្រះឥន្ទ ព្រះព្រហ្ម មានជីវិតរស់មែនយកមកផ្ទៀងកើតឡើយ។

ព្រះពុទ្ធរូប,ស្តូប, ចេតិយ, ប្រាង្គប្រាសាទ, វិហារ, សាលា, គំនូរដែលមានមកហើយនោះ ឈ្មោះថាជារូបរាងនៃសិល្បៈឬជាលទ្ធផលរបស់សិល្បៈនៃបុព្វបុរសខ្មែរអ្នកគោរពព្រះពុទ្ធសាសនា ឬថាការកសាងវត្ថុទាំងអស់មានព្រះពុទ្ធរូប,ស្តូប,ចេតិយ,ជាដើមនេះទុកជាឧត្តមគតិនៃ ពុទ្ធបរិស័ទក្នុងសម័យបុរាណដើម្បីអោយយើងជាន់ក្រោយឃើញសិល្បៈនៃបុព្វបុរស ហើយយើងក៏អាចចម្លងយកបែបសិល្បៈនោះៗមកទៀង៕៚

# II. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវរបស់ក្រុមខ្ញុំព្រះករុណា គឺមានការស្រាវជ្រាក្នុងបណ្ណាល័យ និង តាមសៀវភៅឯកសារមេរៀនផ្សេងៗនៅក្នុងបណ្ណាល័យ ពុទ្ធិកសាកលវិទ្យា ល័យព្រះសីហនុរាជ និងស្រាវជ្រាវពីសៀវភៅ ប្រវត្តិសាស្ត្រ-ប្រវត្តិសិល្បៈខ្មែរ របស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលរៀបរៀង និងបង្រៀនដោយ ជី រដ្ឋា។ មិនតែប៉ុណ្ណោះក្រុមខ្ញុំព្រះករុណាបានស្រាវជ្រាវក្នុងអ៊ីនធើណេតតាមរយអាស័យដ្ឋាន http://toukmeas.blogspot.com និងតាមរយ www.5000-year.org ជាដើម។ ក្នុងនោះផងដែរយើងបានសង្កេតពិនិត្យន័យ នៅក្នុងអត្ថបទយ៉ាងយកចិត្តទុកដាក់ក្នុងការស្រាវជ្រាវនេះដែរ។

១.សៀវភៅ ប្រវត្តិសាស្ត្រ-ប្រវត្តិសិល្បៈខ្មែរ

២. សៀវភៅ ទស្សនាវដ្ដីកម្ពុជាសូរិយា

៣.ក្នុង Website៖http://toukmeas.blogspot.com

៤. ក្នុង Website៖ www.5000-year.org

៥. ការសាកសួរតាមរយសាស្ត្រាផ្សេងៗនៅពាក្យពេចន៍មួយចំនួន

៦. ហើយនឹងពិក្សាក្នុងក្រុមជាពិសេសផងដែរ

៧. នឹងយកចេញពី មង្គលទីបនីសូត្រភាគទី១ ។

# III. លទ្ធផល

បើតាមការឈ្វេងយល់មកយើងឃើញថា សិល្បៈដែលកើតអំពីផលនោះ សំដៅយកវត្ថុផ្សេងៗមានចេតិយ ឬព្រះពុទ្ធរូប ប្រាង្គ បាសាទ វិហារ សាលា និង គំនូរជាដើម ដែលបុព្វបុរសបានសាងទុកមកហើយ ដោយហុចអោយយើងបាន ឃើញជំណាងស្នាដៃដ៏ស្ទាត់ជំនាញ ឬមិនស្ទាត់ជំនាញជារូបដែលមានបែបភាព ទ្រង់ទ្រាយ មានក្បាច់រចនាតាមជំនាន់ តាមសម័យជូនផលដល់យើង ដើម្បីអោយ យើងឃើញគ្រប់បែបយ៉ាងរបស់វប្បធម៌ នៃបុព្វបុរសតាមសម័យនោះៗ។ ពាក្យថា "ផល" ប្រែថា "កំរៃ ផ្លែឈើ សេចក្ដីចំរើន សេចក្ដីរុងរឿង សេចក្ដីសំរេចដូចបំណង លាភយស រង្វាន់" ។

# IV. សេចក្តីសន្និដ្ឋាន

ក្រោយពីធ្វើកិច្ចការស្រាវជ្រាវនៅបណ្ណាល័យពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងកន្លែងផ្សេងៗស្តីពីប្រធានបទ ផលសិប្បៈ សិល្បៈកើតអំពីផលនេះរួចមកខ្ញុំព្រះករុណា ជាក្រុមទី១ បានសង្កេតឃើញថា **សិល្បៈ** កើតអំពីផលនោះសំដៅយកការហាត់រៀនក្នុងផ្លូវសិល្បៈ របស់មនុស្ស ដែលសំលឹងឃើញផលដែលត្រូវបាន ការហាត់រៀននោះក៏ចេះតែខំតស៊ូមិនខ្លាចឧបសគ្គណាមួយដោយមានបំណងចំពោះផលជានិទស្សន៍ មួយទៀតសិល្បៈនេះរាប់ថាជាផ្លូវអាជីព មួយដ៏ប្រសើរដែលនាំអោយមនុស្សមានជីវភាពខ្ពង់ខ្ពស់ **ឧទាហរណ៍:** ដូចជាសិល្បៈខាងការ **រចនាព្រះពុទ្ធរូប, ស្តូប ,ចេតិយ ,ប្រាង្គ ប្រាសាទ, វិហារ , សាលា, គំនូរ** ,និងការរចនាផ្សេងៗ របស់បុព្វបុរសដែលវិវត្តមកដល់យើងសព្វថ្ងៃ អោយយើងបានឃើញជាភស្តុតាងយ៉ាងជាក់ស្តែង ។ សិល្បៈរបស់យើងជាន់ក្រោយឈ្មោះថា កើតមកអំពីផលសិល្បៈនៃបុព្វបុរសដែលបានផ្តល់ ទស្សនៈអោយយើង ។ រូបភាពទាំងអស់ដែលបុព្វបុរសខ្មែរកសាងឡើងដោយថ្មក្តីដោយឥដ្ឋក្តី ឈ្មោះថាជារូបសិល្បៈ ស្ថាពរ មានមកយូរហើយ ដើម្បីជានិទស្សន៍បង្ហាញយើងជាន់ក្រោយ។

# V. ឧបសម្ព័ន្ធ



ព្រះពុទ្ធរូបនាគប្រក់



ព្រះអង្គទ្រង់សម្ដែងធម្មចក្រ



ស្តូប ព្រះបាទ នរោត្តម



ព្រះសក្យមុនីចេតិយ្យ (ចេតិយ)



ព្រះវិហារ



ប្រាសាទ



សកម្មភាពក្រុម ពិភាក្សាគ្នា ក្នុងបណ្ណាល័យ



សកម្មភាពក្រុម ពិភាក្សាគ្នា ក្នុងបណ្ណាល័យ (ព



ព្រះមហា ភុន ធារិទ្ធ



ព្រះមហា ម៉ៅ ត្រា



និស្សិត ឈូក ប៊ុនធឿន

# VI. ឯកសារយោង

១.សៀវភៅ ប្រវត្តិសាស្រ្ត-ប្រវត្តិសិល្បៈខ្មែរ
២. សៀវភៅ ទស្សនាវដ្ដីកម្ពុជាសូរិយា
៣.ក្នុង Website៖http://toukmeas.blogspot.com
៤. ក្នុង Website៖ www.5000-year.org
៥. ការសោកសួរតាមរយសាស្រ្តាផ្សេងៗនៅពាក្យពេចន៍មួយចំនួន
៦. ហើយនឹងពិក្សាក្នុងក្រុមជាពិសេសផងដែរ
៧. នឹងយកចេញពី មង្គលទីបនីសូត្រភាគទី១ ។